**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤១ សសរ

## សេចក្តីសម្រេច

### ស្តីពីការបង្កើតគណៈបញ្ជាការ ការពារសន្តិសុខ សុវត្ថិភាព ជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន នៅភូមិសាស្ត្រខណ្ឌដូនពេញ រាជធានីភ្នំពេញ ហៅកាត់ ( X2 )

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤១៦ / ៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់ របស់រាជរដ្ឋាភិបាល ។

## សម្រេច

**ប្រការ១:** បង្កើតគណៈបញ្ជាការ ការពារសន្តិសុខ សុវត្ថិភាព ជូនសម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅភូមិសាស្ត្រខណ្ឌដូនពេញ រាជធានីភ្នំពេញ ហៅកាត់ ( X2 ) ដែលមានសមាសភាពដូចខាងក្រោម៖

1. ឯកឧត្តម នាយឧត្តមសេនីយ៍ **ហ៊ុយ ពិសិដ្ឋ** អនុរដ្ឋលេខាធិការក្រសួងការពារជាតិ និងជានាយករងខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី **ប្រធាន**
2. ឯកឧត្តម នាយឧត្តមសេនីយ៍ **យូ ស៊ុនឡុង** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ **អនុប្រធាន**
3. មេបញ្ជាការយោធភូមិភាគពិសេស **អនុប្រធាន**
4. ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ **អនុប្រធាន**
5. ឯកឧត្តម នាយឧត្តមសេនីយ៍ **ទូច ណារ៉ុថ** អគ្គស្នងការរង អគ្គស្នងការដ្ឋាននគរបាលជាតិ និងជា ប្រធាននាយកដ្ឋានអង្គរក្ស **អនុប្រធាន**
6. ឯកឧត្តម នាយឧត្តមសេនីយ៍ **ជួន សុវណ្ណ** អគ្គស្នងការរង អគ្គស្នងការដ្ឋាននគរបាលជាតិ និងជា ស្នងការ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ **អនុប្រធានអចិន្ត្រៃយ៍**

7. ឧត្តមសេនីយ៍ឯក **អ៊ុច សារិទ្ធ** មេបញ្ជាការរង និងជា នាយសេនាធិការ បញ្ជាការដ្ឋានអង្គរក្ស **សមាជិកអចិន្ត្រៃយ៍**
8. ឧត្តមសេនីយ៍ឯក **ឡៅ សារុន** មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស **សមាជិក**
9. ឧត្តមសេនីយ៍ឯក **ម៉ែ សារឿន** នាយរងសេនាធិការ បញ្ជាការដ្ឋានអង្គរក្ស **សមាជិក**
10. ឧត្តមសេនីយ៍ឯក **ទី សំណាង** នាយរងសេនាធិការ បញ្ជាការដ្ឋានអង្គរក្ស **សមាជិក**
11. ឧត្តមសេនីយ៍ឯក **ម៉ែន សារ៉ាត់** ស្នងការ ស្នងការដ្ឋានប្រតិបត្តិការ បញ្ជាការដ្ឋានអង្គរក្ស **សមាជិក**
12. មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ **សមាជិក**
13. មេបញ្ជាការកងអន្តរាគមន៍ចំណុះបញ្ជាការដ្ឋានអង្គរក្ស **សមាជិក**

**ប្រការ២:** គណៈបញ្ជាការ មានភារកិច្ចដូចខាងក្រោម ៖

- ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈនៅជុំវិញភូមិគ្រឹះសម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ដែលស្ថិតក្នុងភូមិសាស្ត្រខណ្ឌដូនពេញ រាជធានីភ្នំពេញ ។
- ការពារ តាមដងផ្លូវធ្វើដំណើររបស់សម្តេចតេជោ នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដោយសហការជាមួយ កំលាំងមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ។
- ដោះស្រាយ និងទប់ស្កាត់នូវរាល់បញ្ហា ដែលកើតមានឡើងជាយថាហេតុ នៅមុខ និងជុំវិញភូមិគ្រឹះសម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ដូចជាបាតុកម្ម កូដកម្ម ឬការតវ៉ាផ្សេងៗ ក្នុងភូមិសាស្ត្រខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- អនុប្រធាន និងសមាជិក គណៈបញ្ជាការ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈបញ្ជាការ ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*ថ្ងៃ ចន្ទ ៤ កើត ខែ ទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៨*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
- អគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- កងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com